CDRI
Cambodia Development Resource Institute
សង្ខេបគោលនយោបាយ
ឆ្នាំ២០២៥ លេខ០៤

# ការកសាងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាស្ទែមនៅប្រទេសកម្ពុជា៖ ដំណើរឆ្ពោះទៅរកអន្តរាគមន៍គោលនយោបាយនាពេលអនាគត

**ញ៉ែម ដាវុធ**
អ្នកស្រាវជ្រាវរង វិទ្យាស្ថាន CDRI

**ជា សត្យា**
អ្នកស្រាវជ្រាវ វិទ្យាស្ថាន CDRI

**ហេង សុខមាន**
ជំនួយការស្រាវជ្រាវ វិទ្យាស្ថាន CDRI

របៀបយោងអត្ថបទនេះ៖
Nhem Davut, Chea Sathya and Heng Sok Mean. 2025. *STEM Teacher Capacity Building in Cambodia: Towards Future Policy Interventions.* Policy Brief 2025, No. 04. Phnom Penh: CDRI.

## សារសំខាន់ៗ

- ក្នុងចំណោមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាច្រើន សកម្មភាពដែលផ្តោតលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម-STEM) ភាគច្រើន រួមមាន សិក្ខាសាលា និងការបណ្តុះបណ្តាលនៅក្នុងសាលារៀន។ ជិត ៨០% នៃគ្រូបង្រៀនទាំងអស់ដែលបានចូលរួមក្នុងការសិក្សានេះ (n=401) ធ្លាប់បានចូលរួមសិក្ខាសាលាយ៉ាងហោចណាស់ម្តង ប៉ុន្តែមានគ្រូបង្រៀនតែពាក់កណ្តាលប៉ុណ្ណោះដែលបានចូលរួមសិក្ខាសាលាដែលផ្តោតលើមុខវិជ្ជាស្ទែមយ៉ាងហោចណាស់ម្តង។
- ការសិក្សានេះបង្ហាញថា មិនមានភាពខុសគ្នារវាងយេនឌ័រ ក្នុងការទទួលបាន ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងមុខវិជ្ជាស្ទែមទេ។ ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នាគឺមានទៅតាមប្រភេទសាលារៀន៖ គ្រូបង្រៀននៅសាលាធនធាន ចូលរួមសិក្ខាសាលាស្ទែមបានច្រើនដង ដោយសារការគាំទ្រលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គម្រោងស្តែបអាប់ (StepUP) ដែលផ្តល់មូលនិធិ និងធនធានដល់សាលារៀនគោលដៅនៃគម្រោង។
- សិក្ខាសាលាស្ទែម ត្រូវបានរៀបចំឡើងដោយគ្របដណ្តប់លើប្រធានបទពាក់ព័ន្ធ និងរួមបញ្ចូលសកម្មភាពប្រកបដោយការចូលរួម ប៉ុន្តែមានបញ្ហាប្រឈមទាក់ទងនឹងវិសាលភាព និងភាពពាក់ព័ន្ធទៅនឹងតម្រូវការរបស់សាលារៀន និងបុគ្គល។ ការតាមដាន និងការគាំទ្រ ធ្វើឡើងមិនទៀងទាត់ទេ អាស្រ័យលើការលើកទឹកចិត្តរបស់គ្រូក្នុងការសម្របខ្លួនទៅតាមការអប់រំស្ទែម។

## សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម-STEM) ត្រូវបានចាត់ទុកជាកត្តាជំរុញដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ នៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តគោលនយោបាយ ស្តីពីការអប់រំស្ទែម ដើម្បីជំរុញសិស្សានុសិស្សឱ្យចុះឈ្មោះចូលរៀនថ្នាក់វិទ្យាសាស្ត្របានកាន់តែច្រើន ដោយដាក់ចេញនូវគោលការណ៍ណែនាំជាច្រើនលើបញ្ហានេះ។ គោលការណ៍ណែនាំទាំងនេះរួមមាន បទប្បញ្ញត្តិយន្តការ កម្មវិធីសិក្សា និងធនធានថ្មីៗ ដែលទាក់ទង

នឹងការអប់រំស្ទែម ក៏ដូចជាការវិនិយោគលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន ការបណ្ដុះបណ្ដាលគ្រូ និងនីតិវិធីត្រួតពិនិត្យ និងវាយតម្លៃ។ គោលនយោបាយស្ដីពីការអប់រំស្ទែមនេះ ក៏មានគោលបំណងផ្ដល់ការលើកទឹកចិត្តដល់គំនិតផ្ដួចផ្ដើមស្ទែមដែរ (MoEYS 2016)។ ជាលទ្ធផល សៀវភៅណែនាំស្ទែម និងអន្តរាគមន៍តាមរយៈការអនុវត្តគម្រោងនានា ក៏បានបង្កើតឡើង។ ជាឧទាហរណ៍ ប្រទេសកម្ពុជាបានផ្ដួចផ្ដើមគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (StepUP) ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៥ ដែលផ្ដោតលើការលើកកម្ពស់ការអប់រំស្ទែមនៅទូទាំង សាលាធនធានចំនួន៥០ សាលាបណ្ដាញចំនួន ១០១ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន ៤ និងសាលាទូទៅចំនួន ១០៣[១] (ADB 2022)។

បើទោះបីជារាជរដ្ឋាភិបាលទទួលស្គាល់ អំពីសារៈសំខាន់នៃការអប់រំស្ទែម សម្រាប់ការឈានទៅដល់គោលដៅអភិវឌ្ឍន៍ឆ្នាំ២០៥០ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែប្រឈមមុខនឹងបញ្ហាធំៗក្នុងការអប់រំស្ទែម។ ការចុះឈ្មោះចូលរៀនគន្លងវិទ្យាសាស្ត្រ បានធ្លាក់ចុះយ៉ាងខ្លាំងពី ៩០% ក្នុងឆ្នាំ២០១២-២០១៣ មកត្រឹម ៣៤% ក្នុងឆ្នាំ២០២០-២០២១ (Kao, Chea, and Song 2022)។ ទន្ទឹមនឹងនេះ នៅថ្នាក់ឧត្តមសិក្សា សិស្សជាច្រើនដែលរៀនគន្លងវិទ្យាសាស្ត្រ បានប្ដូរទៅវិទ្យាសាស្ត្រសង្គមវិញ ដោយសារលទ្ធផលសិក្សាមិនសូវល្អ និងចាប់អារម្មណ៍តិចតួចលើមុខវិជ្ជាស្ទែម (Kao, Chea, and Song 2024)។ លើសពីនេះ ប្រទេសកម្ពុជាប្រឈមនឹងការខ្វះខាតសម្ភារៈវិទ្យាសាស្ត្រ (ឧទាហរណ៍ បច្ចេកវិទ្យា ឧបករណ៍ពិសោធន៍) និងកង្វះគ្រូបង្រៀនផ្នែកស្ទែម ដែលមានគុណវឌ្ឍិគ្រប់គ្រាន់ ធ្វើឱ្យរារាំងដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការអប់រំស្ទែម (MoEYS 2021)។ បញ្ហាប្រឈមទាំងនេះបង្ហាញឱ្យឃើញថា កត្តាជាច្រើនបានរួមចំណែកដល់និន្នាការអវិជ្ជមានក្នុងការអប់រំស្ទែមនេះ។ ដើម្បីដោះស្រាយបញ្ហានេះ គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ក្នុងការកែលម្អឱ្យប្រសើរឡើងវិញ និងពង្រឹងការអនុវត្តក្នុងការបង្រៀនស្ទែមរបស់ពួកគេ ដោយចូលរួមក្នុងសកម្មភាពកសាងសមត្ថភាព។

ដោយមើលឃើញពីបញ្ហាប្រឈមទាំងនេះ ជាពិសេសបញ្ហាកង្វះគ្រូបង្រៀនស្ទែមមានគុណវឌ្ឍិគ្រប់គ្រាន់ យើងឃើញមានភស្តុតាងតិចតួចអំពីគ្រូបង្រៀនដែលបានចូលរួមក្នុងសកម្មភាពពង្រឹងសមត្ថភាព ដើម្បីបង្កើនជំនាញ និងចំណេះដឹងរបស់ពួកគេ ដែលធ្វើឱ្យមានភាពស្មុគស្មាញដល់កិច្ចខិតខំប្រឹងប្រែងបង្កើនគុណភាព ក្នុងការបង្រៀនមុខវិជ្ជាស្ទែម។ ការសិក្សាស្រាវជ្រាវនេះ បានពិនិត្យលើការអនុវត្តបច្ចុប្បន្ន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀនស្ទែម នៅតាមវិទ្យាល័យមួយចំនួនក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះ ប្រើវិធីសាស្ត្រចម្រុះ ដោយចាប់ផ្ដើមពីការសម្ភាសបែបគុណវិស័យ ដែលធ្វើឡើងចាប់ពីខែធ្នូ ឆ្នាំ២០២៤ ដល់ខែមករា ឆ្នាំ២០២៥ ជាមួយអ្នកពាក់ព័ន្ធចំនួន ៨៩នាក់ មកពីប្រាំខេត្ត និងរាជធានីភ្នំពេញ រួមមាន មន្ត្រីរាជការ នាយកសាលា និងគ្រូបង្រៀនស្ទែម។ បន្ទាប់មក ការប្រមូលទិន្នន័យបែបបរិមាណវិស័យ បានធ្វើឡើងតាមរយៈការចុះធ្វើអង្កេតចាប់ពីខែមីនា ដល់ខែមេសា ឆ្នាំ២០២៥ ជាមួយគ្រូបង្រៀនដែលត្រូវបានជ្រើសរើសចំនួន ៤០១នាក់ មកពីវិទ្យាល័យចំនួន ៦០។ លទ្ធផលរកឃើញពីការសិក្សាស្រាវជ្រាវនេះ ផ្ដល់ជាអនុសាសន៍គោលនយោបាយជាក់លាក់មួយចំនួន។

## លទ្ធផលស្រាវជ្រាវ

### *ឱកាស និងសមធម៌នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ*

ការសិក្សាស្រាវជ្រាវ បានបង្ហាញពីកម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដ៏សម្បូរបែប សម្រាប់គ្រូបង្រៀនថ្នាក់វិទ្យាល័យនៅប្រទេសកម្ពុជា។ កម្មវិធីទាំងនេះរួមមានគំនិតផ្ដួចផ្ដើមថ្នាក់ជាតិ ដូចជា សិក្ខាសាលាតាមគម្រោង និងសកម្មភាពនៅតាមសាលារៀន ដូចជា ការបណ្ដុះបណ្ដាលតាមសាលារៀនដោយផ្ទាល់ ការប្រជុំបច្ចេកទេស ការសង្កេតថ្នាក់រៀន និងការបង្រៀន

[១] សាលាមធ្យមសិក្សាទុតិយភូមិកម្ពុជា នៅពេលធ្វើការសិក្សាស្រាវជ្រាវនេះ ចែកចេញជាបួនប្រភេទគឺ សាលាធនធាន សាលាបណ្ដាញ សាលាធម្មតា និងវិទ្យាល័យបច្ចេកទេសទូទៅ។ ប្រភេទពីរដំបូង រួមជាមួយនឹងសាលាធម្មតា និងវិទ្យាល័យបច្ចេកទេសទូទៅមួយចំនួន បានចូលរួមក្នុងគម្រោង StepUP។

រវាងគ្រូបង្រៀននិងគ្រូបង្រៀនទៅវិញទៅមក។ លើសពីនេះ សកម្មភាពសិក្សាជាលក្ខណៈបុគ្គល ដូចជា ការស្រាវជ្រាវដោយខ្លួនឯងតាមអ៊ីនធឺណិត និងការបន្តការសិក្សាយកសញ្ញាបត្រផ្លូវការ ក៏រួមចំណែកដល់ទិដ្ឋភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅក្នុងប្រទេសកម្ពុជាដែរ។ មិនតែប៉ុណ្ណោះ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលតាមសាលារៀនដោយផ្ទាល់ បានលេចចេញជាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំយ៉ាងសំខាន់ ដែលបានរៀបចំឡើងជាពិសេស ដើម្បីបង្កើនចំណេះដឹង និងជំនាញស្ទែមសម្រាប់គ្រូបង្រៀន។

ទោះបីជាមានការខិតខំប្រឹងប្រែងរបស់ កម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាច្រើនក៏ដោយ គ្រូបង្រៀនដែលបានចូលរួមសិក្ខាសាលាស្ទែម គឺនៅតែមានកម្រិត។ ខណៈមានគ្រូបង្រៀន ៨០% បានចូលរួមសិក្ខាសាលាយ៉ាងហោចណាស់ម្តង នៅក្នុងអាជីពបង្រៀនរបស់ពួកគេ មានតែគ្រូបង្រៀនប្រហែល ៥០% ប៉ុណ្ណោះ ក្នុងចំណោមគ្រូបង្រៀនដែលចូលរួមក្នុងអង្កេត ដែលបានចូលរួមក្នុងសិក្ខាសាលា ដែលទាក់ទងនឹងប្រធានបទស្ទែម ដូចជា ការសិក្សាតាមបែបរិះរក (IBL) ការរួមបញ្ចូលបច្ចេកវិទ្យា ឬទ្រឹស្តីអំពីស្ទែម។ អត្រាចូលរួមសិក្ខាសាលាក្រោមប្រធានបទផ្សេងៗទៀត ដូចជា ការសិក្សាតាមបែបគម្រោង (PjBL) ប្រតិបត្តិការសម្ភារៈបែបវិទ្យាសាស្ត្រ ការវាយតម្លៃ ការធ្វើការពិសោធន៍ និងការសិក្សាអន្តរមុខវិជ្ជាផ្នែកស្ទែម (សូមមើលរូបភាពទី១) គឺមានកម្រិតទាបជាងនៅប្រធានបទផ្សេងទៀត ដោយមានគ្រូបង្រៀនតែ ២០-៣០% ប៉ុណ្ណោះ ដែលបានចូលរួមសិក្ខាសាលាក្រោមប្រធានបទទាំងនេះ។ លើសពីនេះ ការបានទៅចូលរួមសិក្ខាសាលាស្ទែមនានា គឺមិនមានការរើសអើងយេនឌ័រទេ ប៉ុន្តែមានភាពខុសគ្នាទៅតាមប្រភេទសាលារៀន។ ទិន្នន័យស្រាវជ្រាវបង្ហាញថា គ្រូបង្រៀននៅសាលាធនធានមានឱកាសច្រើនជាងសាលាផ្សេងៗ ក្នុងការទទួលបានការចូលរួមសិក្ខាសាលាស្ទែម។ គ្រូបង្រៀននៅសាលារៀនបណ្ដាញ មានឱកាសតិចជាងគ្រូបង្រៀននៅសាលាធនធាន ហើយទន្ទឹមនឹងនេះដែរ គ្រូបង្រៀននៅសាលាទូទៅ មិនសូវទទួលបានការចូលរួមនោះទេ។ លទ្ធផលនេះបង្ហាញថា ឱកាសចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងការអប់រំស្ទែម ត្រូវបានជំរុញជាចម្បងដោយអន្តរាគមន៍របស់គម្រោង ដោយសារសាលារៀនទាំងនេះ គឺជានៅក្រោមគម្រោងស្តែបអាប់ ដែលផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងបរិយាកាសបង្រៀនដែលមានការគាំទ្រខ្ពស់ ដើម្បីលើកកម្ពស់ដល់ការ

រូបភាពទី១៖ ការចូលរួមរបស់គ្រូបង្រៀនលើប្រធានបទស្ទែម (n=401)




ប្រភព៖ ឯកសារពិភាក្សារបស់អ្នកនិពន្ធ

អប់រំស្ទែម។ ហេតុដូច្នេះហើយ គ្រូបង្រៀនជាច្រើននៅសាលាធនធាន និងសាលារៀនបណ្តាញទាំងនេះមានការយល់ដឹង និងចូលរួមបានច្រើននៅក្នុងការអនុវត្តស្ទែម បើធៀបនឹងគ្រូបង្រៀននៅវិទ្យាល័យផ្សេងពីនេះ។ ភស្តុតាងស្រាវជ្រាវនេះបញ្ជាក់ថា ទោះបីជាការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំប្រកបដោយសមធម៌ គឺជាអាទិភាពនៅក្នុងក្របខណ្ឌការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនថ្នាក់ជាតិក៏ដោយ (MoEYS 2019) ក៏មានបញ្ហាប្រឈមមួយចំនួនក្នុងបរិបទនៃការអប់រំស្ទែម ដែលប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

នៅក្នុងប្រទេសកម្ពុជា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលាបណ្តាញ ហាក់ពុំសូវមានសកម្មភាពប៉ុន្មានទេ មានតែនៅកម្រិតសាលារៀនប៉ុណ្ណោះដែលមានសកម្មភាព ដូចជាការប្រជុំបច្ចេកទេស ដែលជាវេទិកាទូទៅសម្រាប់ការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ដោយមានគ្រូបង្រៀនជាង ៥៣% បានចូលរួមកិច្ចប្រជុំចំនួន ៤-៩ដងជារៀងរាល់ឆ្នាំ។ ជាធម្មតាកិច្ចប្រជុំនេះពិភាក្សាដោះស្រាយតែបញ្ហាគរុកោសល្យទូទៅប៉ុណ្ណោះ មិនមែនជាការប្រជុំលើខ្លឹមសារស្ទែមណាមួយទេ។ ជាក់ស្តែង ពុំមានការចែករំលែកចំណេះដឹងលើប្រធានបទស្ទែម រវាងគ្រូបង្រៀននិងគ្រូបង្រៀននៅឡើយទេ។ ជាឧទាហរណ៍ គេរំពឹងថា អ្នកចូលរួមសិក្ខាសាលានឹងចែករំលែកនូវអ្វីដែលពួកគេបានរៀន ដល់គ្រូបង្រៀនដទៃដែលមិនបានចូលរួម ប៉ុន្តែពួកគាត់ពុំបានអនុវត្តដូចការរំពឹងទុកឡើយ។ នេះគឺបណ្តាលមកពីកត្តារួមផ្សំជាច្រើន ដូចជា សមត្ថភាពគ្រូបង្រៀនមានកម្រិត ក្នុងការផ្សព្វផ្សាយចំណេះដឹងដែលបានសិក្សា កង្វះចំណាប់អារម្មណ៍ពីសហការី និងការគាំទ្រមិនគ្រប់គ្រាន់ពីថ្នាក់ដឹកនាំសាលា ដើម្បីពង្រឹង ឬសម្របសម្រួលដំណើរការចែករំលែកចំណេះដឹង។ គ្រូបង្រៀនជាច្រើននាក់បានកត់សម្គាល់ថា វាមានការលំបាកក្នុងការចែករំលែកអ្វីដែលខ្លួនបានរៀនក្នុងរយៈពេលពីរ ឬបីថ្ងៃ ឱ្យមានប្រសិទ្ធភាពក្នុងរយៈពេលត្រឹមតែមួយ ឬពីរម៉ោង។ ភស្តុតាងស្រាវជ្រាវនេះ បានបង្ហាញពីសារៈសំខាន់នៃគំនិតផ្តួចផ្តើម ដែលត្រូវចាប់ពីថ្នាក់ក្រោមដល់ថ្នាក់លើ ក្នុងការលើកកម្ពស់ការអនុវត្តស្ទែម នៅក្នុងចំណោមគ្រូបង្រៀនដូចគ្នា។

## *គុណភាពនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្នុងការអប់រំស្ទែម និងការបង្រៀនស្ទែម*

### *ខ្លឹមសារ និងសកម្មភាពនានា*

ក្រៅពីឱកាសទទួលបាន កម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងការអប់រំស្ទែម មានទាំងចំណុចខ្លាំង និងដែនកំណត់។ សិក្ខាសាលាស្ទែម (ឬកម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ) ផ្តល់នូវសកម្មភាពប្រកបដោយការចូលរួម និងខ្លឹមសារស្ទែមដែលពាក់ព័ន្ធជាច្រើន។ ឧទាហរណ៍ គ្រូបង្រៀនមានឱកាសសហការជាមួយគ្រូបង្រៀនមុខវិជ្ជាផ្សេងទៀត ដើម្បីរៀបចំផែនការមេរៀន ធ្វើបទបង្ហាញ ឬអនុវត្តផែនការ និងទទួលបានមតិកែលម្អពីគ្រូបណ្តុះបណ្តាល។ គ្រូបង្រៀនមួយចំនួនថែមទាំងបានអនុវត្តសកម្មភាពថ្មីៗនៅក្នុងថ្នាក់រៀនទៀតផង។ ទោះជាយ៉ាងណាក្តី វានៅតែមានកង្វល់មួយចំនួន។ ជាឧទាហរណ៍ វគ្គបណ្តុះបណ្តាលច្រើនតែមានប្រធានបទច្រើននៅពេលតែមួយ ដែលអាចធ្វើឱ្យសិក្ខាកាមមួយចំនួនចាប់មិនបាន និងមិនអាចអនុវត្តអ្វីដែលពួកគេបានរៀន។ សិក្ខាកាមក៏នៅខ្វះបទពិសោធន៍ក្នុងការសិក្សាអន្តរមុខវិជ្ជា ដោយសារជាធម្មតា ការបណ្តុះបណ្តាលបែងចែកគ្រូបង្រៀន ទៅតាមមុខវិជ្ជាដោយកាត់បន្ថយឱកាសសហការគ្នាលើអន្តរកម្មប្រធានបទ។ លើសពីនេះ សិក្ខាសាលាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំភាគច្រើន គឺជាព្រឹត្តិការណ៍ដែលមានតែម្តង ដោយមានការតាមដានផ្តល់ការគាំទ្រតិចតួច ដើម្បីពង្រឹងការរៀនសូត្រ ឬជាជំនួយក្នុងការអនុវត្តអ្វីដែលបានរៀន។ បើមិនមានការគាំទ្រជាប្រចាំ និងការណែនាំជាក់ស្តែងទេ គ្រូបង្រៀនជាច្រើន បានត្រលប់ទៅប្រើវិធីសាស្ត្របង្រៀនបែបបុរាណវិញ (ឧទាហរណ៍ ការបង្រៀនមេរៀន ការសរសេរមេរៀនៅលើក្តារខៀន ឬឱ្យលំហាត់សិស្សធ្វើ) ដោយសារតែពួកគាត់ខ្វះទំនុកចិត្ត និងធនធាន ក្នុងការអនុវត្តយុទ្ធសាស្ត្រថ្មីៗឱ្យមានប្រសិទ្ធភាព។

### *ភាពសមស្របគ្នា និងការសម្របខ្លួន*

ខ្លឹមសារសិក្ខាសាលា មិនបានកែសម្រួលឱ្យសមស្របទៅនឹងប្រវត្តិសិក្សា និងកម្រិតបទពិសោធន៍ផ្សេងគ្នាៗរបស់គ្រូបង្រៀនទេ ដោយអ្នកខ្លះយល់ថាខ្លឹមសារមានកម្រិតខ្ពស់ពេក ខណៈអ្នកខ្លះទៀតគិតថា វាសាមញ្ញពេក។ ជាលទ្ធផល ខណៈគ្រូបង្រៀនមួយចំនួន

អាចយកសកម្មភាពស្នែមថ្មីទៅអនុវត្តបាន អ្នកខ្លះទៀតបានត្រលប់ទៅប្រើទម្លាប់នៃការបង្រៀនចាស់វិញ។ គ្រូបង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងគណិតវិទ្យាមួយចំនួន ថែមទាំងយល់ឃើញថា មុខវិជ្ជារបស់ពួកគាត់ពុំពាក់ព័ន្ធនឹងការអប់រំស្ទែមទៀតផង។ ជាងនេះទៅទៀត ការធានាឱ្យមានភាពសមស្របទៅនឹងបរិបទជាក់ស្តែងរបស់សាលារៀន ក៏ជាបញ្ហាគួរឱ្យព្រួយបារម្ភមួយផងដែរ ព្រោះគ្រូបង្រៀនមួយចំនួនបានរាយការណ៍ថា ពួកគាត់ខ្វះសម្ភារៈចាំបាច់សម្រាប់អនុវត្តចំណេះដឹង និងជំនាញដែលបានទទួលពីការបណ្តុះបណ្តាល។ លើកលែងតែសាលាធនធាន ដែលមានធនធានច្រើនជាងគេ សាលារៀនជាច្រើនផ្សេងទៀត ប្រឈមនឹងបញ្ហាខ្វះសម្ភារៈ និងឧបករណ៍ ដែលជាឧបសគ្គសម្រាប់គ្រូបង្រៀន ក្នុងការអនុវត្តអ្វីដែលពួកគាត់បានរៀនតាមរយៈកម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ លើសពីនេះ វប្បធម៌ដែលផ្តោតខ្លាំងលើការប្រឡង បានជំរុញឱ្យគ្រូបង្រៀនផ្តល់អាទិភាពដល់ការត្រៀមខ្លួនរបស់សិស្សសម្រាប់ការប្រឡង ជាជាងការអភិវឌ្ឍ និងអនុវត្តវិធីសាស្ត្របង្រៀនដែលជំរុញឱ្យមានការចូលរួមសកម្មរបស់សិស្ស។ ជាពិសេស សិស្សគន្លងវិទ្យាសាស្ត្រសង្គម មិនសូវយកចិត្តទុកដាក់លើមុខវិជ្ជាស្ទែមទេ ដោយជឿថាមុខវិជ្ជាស្ទែមមិនពាក់ព័ន្ធនឹងការប្រឡង ហើយគ្រូបង្រៀន ក៏មិនចង់ទទួលយកគរុកោសល្យប្រកបដោយនវានុវត្តន៍ដែលមិនមាននៅក្នុងវិញ្ញាសារប្រឡងនោះដែរ។ បញ្ហាចុងក្រោយគឺ ទំហំថ្នាក់រៀនធំ ដែលនាំឱ្យមានការលំបាកក្នុងការគ្រប់គ្រងសកម្មភាពស្ទែមដោយផ្ទាល់។ កត្តាទាំងនេះ រួមផ្សំជាមួយនឹងកម្មវិធីសិក្សាដែលមានមាតិកាច្រើនផង ធ្វើឱ្យមានពេលវេលា និងភាពបត់បែនតិចតួចសម្រាប់ការសិក្សាតាមបែបគម្រោង និងការអនុវត្តអន្តរកម្មស្ទែមផ្សេងទៀត។

## អនុសាសន៍

សង្ខេបគោលនយោបាយនេះ ផ្តល់ជាអនុសាសន៍សំខាន់ៗ ក្នុងគោលបំណងពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សំដៅធ្វើឱ្យការអប់រំស្ទែម មានភាពប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា។ គំនិតដែលបានស្នើឡើងទាំងនេះ គឺផ្តល់ជូនចំពោះភាគីពាក់ព័ន្ធទាំងឡាយ ដើម្បីជំរុញប្រព័ន្ធអប់រំប្រកបដោយសមធម៌ ចីរភាព និងប្រសិទ្ធភាពបន្ថែមទៀត។

### *ជូនចំពោះក្រសួងអប់រំ យុវជន និងកីឡា*

- **ការផ្តល់ឱ្យដែលមានសមធម៌៖** ក្របខ័ណ្ឌការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំឆ្នាំ២០១៩ គិតគូរអំពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀនគ្រប់រូប (MoEYS 2019) ប៉ុន្តែភស្តុតាងបង្ហាញថា សាលារៀននៅតាមជនបទ និងសាលារៀនទូទៅ នៅតែមិនទាន់ទទួលបានវគ្គបណ្តុះបណ្តាលនៅឡើយ។ យុទ្ធសាស្ត្រជាតិ គួរតែផ្តល់អាទិភាពលើសមធម៌ ដោយកំណត់គោលដៅអប្បបរមានៃការទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងការអប់រំស្ទែម សម្រាប់សាលារៀនដែលជួបការលំបាក។ ទោះបីជាគ្រូបង្រៀនមកពីសាលាទូទៅមួយចំនួន មានឱកាសចូលរួមវគ្គបណ្តុះបណ្តាលក៏ដោយ ក៏ពួកគាត់មិនអាចអនុវត្តការអប់រំស្ទែមនៅក្នុងថ្នាក់រៀនបានដែរ ដោយសារតែធនធានមានកម្រិត។ ដូច្នេះហើយ សាលារៀនទាំងនោះ គួរតែទទួលបានសម្ភារៈ និងឧបករណ៍ចាំបាច់ សម្រាប់អនុវត្តន៍ការណែនាំស្ទែមថ្មីប្រកបដោយប្រសិទ្ធភាព នៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ។

- **ការលើកកម្ពស់ភាពពាក់ព័ន្ធរបស់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈការបណ្តុះបណ្តាលតាមបរិបទ និងជាបន្តបន្ទាប់៖** ក្រសួងអប់រំ យុវជន និងកីឡា គួរតែធានាថា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺបានសម្របទៅតាមប្រវត្តិសិក្សា ចំណាប់អារម្មណ៍ និងបរិបទរបស់សាលារៀន តាមរយៈការវាយតម្លៃពីសមត្ថភាព និងការលើកទឹកចិត្តដល់គ្រូបង្រៀនមុនពេលបណ្តុះបណ្តាល (សូមមើល King 2018)។ ការធ្វើបែបនេះ អាចឱ្យយើងបែងចែក វគ្គណែនាំអំពីការអប់រំស្ទែម សម្រាប់អ្នកដែលចាប់ផ្តើមដំបូង និងមេរៀនគរុកោសល្យកម្រិតខ្ពស់ សម្រាប់គ្រូបង្រៀនដែលមានបទពិសោធន៍ ហើយផ្តល់តម្លៃលើការលើកទឹកចិត្ត និងការបើកចំហចំពោះនវានុវត្តន៍។ ខ្លឹមសារការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ត្រូវតែឆ្លុះបញ្ចាំងពីតថភាពនៃវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា ដោយប្រើឧទាហរណ៍ជាក់ស្តែង ដែលទាក់ទងនឹងថ្នាក់រៀនធំ និងចម្រុះ ជាជាងការប្រើឧទាហរណ៍ករណីគំរូៗ។ សកម្មភាពបង្រៀនបែបថ្មី គួរតែត្រូវបានសាកល្បងនៅកម្រិតមូលដ្ឋានជាមុនសិន មុនពេលធ្វើការផ្សព្វផ្សាយនៅក្នុងការបណ្តុះបណ្តាល។ ក្រសួង

អប់រំ យុវជន និងកីឡា ក៏គួរតែបង្រួមវិសាលភាពនៃការបណ្តុះបណ្តាល និងអនុវត្តវិធីសាស្ត្របន្តបន្ទាប់គ្នា ដែលផ្តោតការយកចិត្តទុកដាក់ សង្កត់ធ្ងន់លើខ្លឹមសារឱ្យស៊ីជម្រៅ និងការអនុវត្តនៅក្នុងថ្នាក់រៀន។ ជំនួសឱ្យការមានប្រធានបទជាច្រើន ក្នុងពេលតែមួយ វគ្គបណ្តុះបណ្តាលនីមួយៗ គួរតែផ្តោតលើប្រធានបទមួយ ដូចជា ការសិក្សាតាមបែបរិះរក ឬការសិក្សាតាមបែបគម្រោង បន្ទាប់មកត្រូវមានការឆ្លុះបញ្ចាំង និងមតិកែលម្អពីមិត្តភ័ក្តិ នៅក្នុងវគ្គក្រោយៗទៀត។ វគ្គបណ្តុះបណ្តាលដែលមានរចនាសម្ព័ន្ធទាំងនេះ បើរៀបចំអំឡុងពេលវិស្សមកាលឆមាស នឹងជួយគ្រូបង្រៀនអនុវត្តវិធីសាស្ត្រថ្មីបន្តិចម្តងៗ និងពង្រឹងទំនុកចិត្តលើការបង្រៀនស្ទែម។

- **ការផ្តល់សិទ្ធិអំណាចដល់ថ្នាក់ដឹកនាំសាលារៀនក្នុងការគាំទ្រដល់គ្រូបង្រៀន៖** ក្រសួងអប់រំ យុវជន និងកីឡា គួរតែផ្តល់ការណែនាំ និងការបណ្តុះបណ្តាលច្បាស់លាស់ ដល់ថ្នាក់ដឹកនាំសាលារៀន ដើម្បីឱ្យពួកគាត់តាមដាន និងគាំទ្រយ៉ាងសកម្មនូវការអនុវត្តវិធីសាស្ត្រគរុកោសល្យស្ទែមថ្មីរបស់គ្រូបង្រៀន។ ភស្តុតាងស្រាវជ្រាវបង្ហាញថា នាយកសាលាជាច្រើនតែងតែបន្ទោសពីការខ្វះខាតចំណេះដឹងលើខ្លឹមសារ ក្នុងការបណ្តុះបណ្តាលថា ជាឧបសគ្គដល់ការគាំទ្រគ្រូបង្រៀន។ ទោះជាយ៉ាងណា តាមពិតតួនាទីរបស់នាយកសាលា គឺផ្តោតតែលើការសម្របសម្រួលសកម្មភាពនានា ដូចជា ការពិភាក្សាជាមួយគ្រូបង្រៀនអំពីរបៀបបញ្ចូលវិធីសាស្ត្របង្រៀនថ្មីៗទៅក្នុងថ្នាក់រៀន របៀបគាំទ្រការអនុវត្ត និងរបៀបវាយតម្លៃការអនុវត្ត។ លទ្ធផលស្រាវជ្រាវនេះបង្ហាញពីតម្រូវការបណ្តុះបណ្តាល សម្រាប់នាយកសាលាដែលផ្តោតលើការគាំទ្រ និងការណែនាំផ្ទាល់ដល់គ្រូបង្រៀន។

- **ការអនុវត្តប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម៖** គោលនយោបាយស្តីពី ការចូលរួមការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការលើកទឹកចិត្តមានហើយ ប៉ុន្តែយោងតាមភស្តុតាងនៃការស្រាវជ្រាវ វាទទួលស្គាល់តែតាមកំណត់ត្រានៃការចូលរួមការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំប៉ុណ្ណោះ ដែលមានឥទ្ធិពលមិនទៀងទាត់លើការផ្លាស់ប្តូរផ្នែកអប់រំ ។ ដើម្បីជំរុញឱ្យមានការចូលរួមដោយចីរភាព និងការកែលម្អជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា គួរតែបង្កើតប្រព័ន្ធលើកទឹកចិត្តដែលផ្តល់រង្វាន់ផ្អែកលើសមិទ្ធកម្មរៀននិងបង្រៀន និងផ្អែកលើលទ្ធផលអប់រំជាវិជ្ជមាននៅក្នុងការអប់រំស្ទែម ជាជាងការទទួលស្គាល់តែការចូលរួមនៅក្នុងសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

- **ដោះស្រាយឧបសគ្គរចនាសម្ព័ន្ធជាប្រព័ន្ធ៖** ក្រសួងអប់រំ យុវជន និងកីឡា គួរតែដោះស្រាយបញ្ហាប្រឈមជាប្រព័ន្ធ ដូចជា ថ្នាក់ដែលមានទំហំធំ ឧបសគ្គធនធាន កង្វះគ្រូបង្រៀន និងវប្បធម៌ដែលផ្តោតខ្លាំងលើការប្រឡង ដែលរារាំងដល់ការអប់រំស្ទែម។ ការប្រឡងថ្នាក់ទី១២នៅប្រទេសកម្ពុជា បានដាក់សម្ពាធលើសិស្ស និងគ្រូបង្រៀន ឱ្យផ្តោតលើការទន្ទេញចាំ លើការស្ទាត់ជំនាញទស្សនទានស្ទែម ដែលផ្តល់សារៈសំខាន់តិចតួចដល់ការសិក្សាតាមបែបរិះរក ការពិសោធន៍ ឬវិធីសាស្ត្របង្រៀនសម្រាប់ការបង្រៀន និងរៀនតាមបែបគម្រោង។ ក្រសួងអប់រំ យុវជន និងកីឡា គួរតែសម្របការវាយតម្លៃឱ្យត្រូវនឹងគោលដៅរបស់ស្ទែម ដោយសង្កត់ធ្ងន់ទៅលើការគិតបែបត្រិះរិះពិចារណា និងការអនុវត្ត។ លើសពីនេះ ការធ្វើឱ្យសម្ភារៈបរិក្ខារ និងកម្មវិធីសិក្សាប្រសើរឡើង គឺចាំបាច់ណាស់សម្រាប់ការសិក្សាស្ទែម ដែលផ្តោតលើសកម្មភាពសិស្សដោយផ្ទាល់។ បើគ្មានកំណែទម្រង់ទាំងនេះទេ ទោះជាមានកិច្ចខិតខំប្រឹងប្រែងពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំខ្លាំងក៏ដោយ ក៏ប្រហែលជាមិនមានលទ្ធផលល្អ នៅក្នុងការកែលម្អថ្នាក់រៀនដែរ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា ការអនុវត្តស្ទែមនៅក្នុងសាលារៀន ក៏អាស្រ័យលើសមត្ថភាពរបស់គ្រូបង្រៀនផងដែរ។

### *ជូនចំពោះនាយកសាលា និងលោកគ្រូអ្នកគ្រូ*

- **ឈានមុខក្នុងគំនិតផ្តួចផ្តើមអប់រំស្ទែម៖** នាយកសាលាដើរតួនាទីសំខាន់ក្នុងការរៀបចំវប្បធម៌ និងអាទិភាពរបស់សាលារៀន ក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយគួរតែចេញមុខដើរតួជាអ្នកតស៊ូមតិក្នុងការអប់រំស្ទែម ដោយត្រូវធានាថា ការអប់រំស្ទែមជាធាតុផ្សំស្នូលក្នុងការបង្រៀន និងការរៀន ជាជាង

«កម្មវិធីបន្ថែម»។ នេះមានន័យថា នាយកសាលាត្រូវសកម្មក្នុងការលើកកម្ពស់ការអប់រំស្ទែម តាមរយៈការផ្សព្វផ្សាយអំពីសារៈសំខាន់របស់វា ទៅកាន់គ្រូបង្រៀន សិស្សានុសិស្ស និងមាតាបិតា បង្ហាញពីករណីជោគជ័យ និងគម្រោងរបស់សិស្ស និងភ្ជាប់ស្ទែមទៅក្នុងព្រឹត្តិការណ៍នានារបស់សាលារៀន ដើម្បីកសាងចំណូលចិត្តក្នុងការអប់រំស្ទែម។ ក្រៅពីសកម្មភាពទាំងនេះ នាយកសាលាអាចរៀបចំសកម្មភាពស្ទែមឱ្យទៅជាសកម្មភាពរបស់ស្ថាប័ន ដោយបញ្ចូលស្ទែមទៅក្នុងសកម្មភាពរបស់សាលារៀន ដូចជា ការបង្កើតក្លឹបស្ទែម ការលើកទឹកចិត្តឱ្យអនុវត្តគម្រោងអន្តរមុខវិជ្ជា និងការសម្របផែនការសាលារៀន ឱ្យត្រូវទៅតាមអាទិភាពស្ទែមរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ម្យ៉ាងទៀត នាយកសាលាគួរមានយុទ្ធសាស្ត្រច្បាស់លាស់ ក្នុងការបែងចែកធនធានឱ្យមានប្រសិទ្ធភាព ដោយផ្តល់អាទិភាពដល់ការប្រើប្រាស់ថវិកាដែលមានកម្រិត សម្រាប់សកម្មភាពពាក់ព័ន្ធនឹងស្ទែម ដូចជា ការពិសោធវិទ្យាសាស្ត្រដែលចំណាយតិច ការផ្គត់ផ្គង់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងការគាំទ្រឱ្យគ្រូបង្រៀនចូលរួមក្នុងសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ជាមួយគ្នានេះ នាយកសាលាអាចប្រើប្រាស់ថវិកាអភិវឌ្ឍន៍សាលារៀន និងពង្រឹងភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីប្រមូល និងប្រើប្រាស់ធនធានបន្ថែម សំដៅបង្កើនផលជះវិជ្ជមានឱ្យបានជាអតិបរមា។ ជាការចាំបាច់ដូចគ្នាដែរ នាយកសាលាគួរបង្កើតបរិយាកាសប្រកបដោយការគាំទ្រសម្រាប់គ្រូបង្រៀន តាមរយៈការផ្តល់ពេលវេលារៀបចំមេរៀន លើកទឹកចិត្តអនុវត្តន៍ការបង្រៀនប្រកបដោយនវានុវត្តន៍ ទទួលស្គាល់គំនិតផ្តួចផ្តើមក្នុងគរុកោសល្យស្ទែម និងធានាថា សាលារៀន និងគ្រូបង្រៀនទាំងអស់ មានឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈដោយស្មើភាព ហើយភ្ជាប់ការអភិវឌ្ឍវិជ្ជាជីវៈទៅនឹងការអនុវត្តនៅក្នុងថ្នាក់រៀនដោយផ្ទាល់។

- **ការផ្តល់ការគាំទ្រ និងការតាមដានយ៉ាងសកម្មដល់គ្រូបង្រៀន៖** នាយកសាលាត្រូវបានលើកទឹកចិត្តឱ្យតាមដានជាប្រចាំនូវវឌ្ឍនភាពរបស់គ្រូបង្រៀន ក្នុងការអនុវត្តវិធីសាស្ត្រស្ទែមថ្មី ផ្តល់នូវមតិយោបល់ស្ថាបនា និងសម្របសម្រួលឱ្យមានការឆ្លុះបញ្ចាំងអំពីខ្លួនឯងជារឿយៗ (សូមមើល King 2018)។ ការគាំទ្រដល់ការបង្កើតកម្មវិធីតម្រង់ទិស និងការណែនាំនៅក្នុងសាលារៀន ក៏ជាកត្តាសំខាន់ផងដែរ។ លើសពីនេះ នាយកសាលាគួរតែបង្កើតឱកាសឱ្យបានទៀងទាត់ សម្រាប់គ្រូបង្រៀន ក្នុងការពិភាក្សាក្រោយរៀនចប់ ឬរៀនពីគ្រូបង្រៀនដទៃ មិត្តភ័ក្តិទៅវិញទៅមកជាដើម ជាពិសេសក្នុងអំឡុងពេលការប្រជុំបច្ចេកទេសដែលគ្រូបង្រៀន អាចចែករំលែកបញ្ហាប្រឈម និងភាពជោគជ័យ ក្នុងការអនុវត្តការបង្រៀនស្ទែម។ តាមរយៈការជំរុញវប្បធម៌កែលម្អជាប្រចាំ និងកិច្ចសន្ទនាប្រកបដោយវិជ្ជាជីវៈ នាយកសាលាអាចធានាថា ការបណ្តុះបណ្តាលនឹងប្រែក្លាយទៅជាការផ្លាស់ប្តូរជាវិជ្ជមានយូរអង្វែង សម្រាប់ការអនុវត្តក្នុងថ្នាក់រៀន។

- **ការបង្កើតផែនការការអភិវឌ្ឍវិជ្ជាជីវៈ៖** គ្រូបង្រៀនគួរតែត្រូវបានលើកទឹកចិត្តក្នុងការព្យាយាមសម្រេចគោលដៅរបស់ខ្លួនក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈសកម្មភាពផ្លូវការ ដូចជា ការអប់រំដែលមានការទទួលស្គាល់ជាផ្លូវការ និងក្រៅផ្លូវការ ដូចជា ការរៀនពីមិត្តភ័ក្តិទៅវិញទៅមក និងការសិក្សាដោយខ្លួនឯងជាដើម ដូចដែលបានរៀបរាប់នៅក្នុងគោលនយោបាយ ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (MoEYS 2019)។ លើសពីនេះ សាលារៀនគួរតែទទួលស្គាល់ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ថាជាកត្តាសំខាន់ក្នុងការកែលម្អគុណភាពបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ នាយកសាលាត្រូវតែដើរតួនាទីសកម្មក្នុងការធ្វើផែនការ និងការផ្តល់ធនធានសម្រាប់គាំទ្រដល់គំនិតផ្តួចផ្តើមការអភិវឌ្ឍវិជ្ជាជីវៈនៅតាមសាលារៀន ជាជាងពឹងផ្អែកតែលើគម្រោងដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ។ វិធីសាស្ត្រអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលផ្អែកលើគ្រូបង្រៀន និងសាលារៀន នឹងជួយធានាបាននូវចីរភាព ភាពពាក់ព័ន្ធ និងភាពសមស្របកាន់តែប្រសើរ ស្របតាមបរិបទ និងតម្រូវការជាក់ស្តែងរបស់គ្រូបង្រៀន និងសាលារៀន។

# ឯកសារយោង


ADB (Asian Development Bank). 2022. "Kingdom of Cambodia: Science and Technology Project in Upper Secondary Education." https://www.adb.org/sites/default/files/project-documents/55134/55134-001-ipp-en.pdf.

Kao, Sovansophal, Phal Chea, and Sopheak Song. 2022. *Upper Secondary School Tracking and Major Choices in Higher Education: To Switch or Not to Switch*. CDRI Working Paper Series No. 133. Phnom Penh: CDRI. https://doi.org/10.64202/wp.133.202203.

———. 2024. "Upper Secondary School Tracking and Major Choices in Higher Education: To Switch or Not to Switch." *Educational Research for Policy and Practice* 23 (1): 89–113. https://doi.org/10.1007/s10671-023-09356-1.

King, Elizabeth Fiona. 2018. "Developing Teacher Capacity in Cambodia: An Expanded Model." *Asian Education and Development Studies* 7 (1): 2–14. https://doi.org/10.1108/aeds-06-2017-0053.

MoEYS (Ministry of Education, Youth and Sport). 2016. *គោលនយោបាយស្តីពីការអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា* [Policy on Science, Technology, Engineering, and Mathematics]. Phnom Penh: MoEYS.

———. 2019. *Continuous Professional Development Framework for Teachers and School Directors*. Phnom Penh: MoEYS.

———. 2021. *Cambodia Secondary Education Blueprint 2030*. Phnom Penh: MoEYS.



**អំពីវិទ្យាស្ថាន**

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI) គឺជាវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍ឯករាជ្យឈានមុខគេរបស់កម្ពុជា។ បង្កើតឡើងក្នុងឆ្នាំ១៩៩០ វិទ្យាស្ថាន CDRI មានបេសកកម្មផលិតចំណេះដឹងអំពីការអភិវឌ្ឍប្រកបដោយគុណភាព មានឥទ្ធិពល និងផលជះ តាមរយៈការស្រាវជ្រាវគោលនយោបាយ និងការអភិវឌ្ឍសមត្ថភាព ដើម្បីរួមចំណែកដល់ភាពរុងរឿងរបស់ប្រទេសកម្ពុជា និងតំបន់។

**សង្ខេបគោលនយោបាយ CDRI** បង្ហាញពីលទ្ធផលរកឃើញសំខាន់ៗ និងផលជះខាងគោលនយោបាយនៃការស្រាវជ្រាវរបស់ CDRI សម្រាប់ទស្សនិកជនដែលមិនមែនជាអ្នកជំនាញ ដោយមានគោលបំណងផ្តល់ព័ត៌មានដល់ការជជែកពិភាក្សាខាងគោលនយោបាយ។

ទស្សនៈដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់វិទ្យាស្ថាន CDRI ក្រុមប្រឹក្សាភិបាល ឬស្ថាប័នដែលអ្នកនិពន្ធកំពុងបម្រើការងារនោះទេ។ វិទ្យាស្ថាន CDRI មិនធានាភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះទេ ហើយមិនទទួលខុសត្រូវចំពោះផលវិបាកណាមួយសម្រាប់ការប្រើប្រាស់ឡើយ។

ការសិក្សានេះ ទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ ២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ដែលអនុវត្តដោយអង្គការមូលនិធិអាស៊ី។

Australian Aid | PONLOK CHOMNES | The Asia Foundation



**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
ផ្លូវលេខ ៥៦ លេខ ៣១៥ ខណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
+៨៥៥ ២៣ ៨៨១៧០១ / ៨៨១៩១៦ / ៨៨៣៦០៣ អ៊ីមែល cdri@cdri.org.kh គេហទំព័រ www.cdri.org.kh



CC BY

អាជ្ញាប័ណ្ណអន្តរជាតិ Creative Commons Attribution 4.0 (CC BY 4.0)
© 2026 CDRI។ អាជ្ញាប័ណ្ណ CC មិនអនុវត្តចំពោះសម្ភារៈរក្សាសិទ្ធិដែលមិនមែនជារបស់ CDRI នៅក្នុងការបោះពុម្ពផ្សាយនេះទេ។